# ទំព័រព័ត៌មានការធ្វើការលើសម៉ោងសម្រាប់អ្នកផ្តល់សេវាកម្មផ្ទាល់ខ្លួន

ទំព័រព័ត៌មាននេះមានគោលបំណងជួយអ្នកផ្តល់សេវាកម្មផ្ទាល់ខ្លួនឲ្យយល់ពីវិន័យអំពីកម្រិតសប្តាហ៍ការងារ និងការធ្វើការលើសម៉ោង ។ សូមទាក់ទងអ្នកគ្រប់គ្រងសំណុំរឿងរបស់អតិថិជន ឬចូល www.dshs.wa.gov/altsa/IPOT សម្រាប់ព័ត៌មានបន្ថែម ។

ព័ត៌មានការធ្វើការលើសម៉ោងទូទៅ

1. តើអ្វីជា 'សប្តាហ៍ការងារ'?
   សប្តាហ៍ការងារចាប់ផ្តើមនៅថ្ងៃអាទិត្យម៉ោង 12:00 ព្រឹក (ពាក់កណ្តាលអាធ្រាត្រ) និងបញ្ចប់នៅថ្ងៃសៅរ៍បន្ទាប់ម៉ោង 11:59 យប់ ។

2. តើអ្វីជាការកម្រិតសប្តាហ៍ការងារ (WWL)?
   WWL គឺជាចំនួនម៉ោងសេវាកម្មសរុបដែលអ្នកអាចធ្វើការក្នុងមួយសប្តាហ៍ការងារ ។ ច្បាប់រដ្ឋវ៉ាស៊ីនតោនឆ្នាំ 2016 កំណត់កម្រិតចំនួនម៉ោងដែលអ្នកផ្តល់សេវាកម្មផ្ទាល់ខ្លួន (IP) អាចធ្វើការក្នុងមួយសប្តាហ៍ការងារ ។ IPs ទាំងអស់មានការកម្រិតសប្តាហ៍ការងារ (WWL) ។ អ្នកអាចត្រឹមតែធ្វើការដល់ WWL របស់អ្នក ពេលដែលចំនួនម៉ោងនោះត្រូវបានចាត់តាំងឲ្យអ្នកដោយអតិថិជនម្នាក់ ឬច្រើន ហើយអតិថិជនដែលអ្នកផ្តល់សេវាកម្ម មានសិទ្ធិទទួលបានចំនួនម៉ោង ។ អតិថិជនមិនអាចចាត់តាំងលើសពីចំនួនម៉ោងប្រចាំខែដែលបានវាយតម្លៃក្នុងគម្រោងថែទាំរបស់ពួកគេទេ ។ WWLs ជួយគ្រប់គ្រងការចំណាយធ្វើការលើសម៉ោង ដើម្បីធានាថាឱកាសសម្រាប់សេវាកម្មនៅតែមានសម្រាប់អ្នកទាំងអស់ដែលត្រូវការវា ។

3. តើ DSHS កំណត់ WWL អចិន្ត្រៃយ៍របស់ខ្ញុំយ៉ាងដូចម្តេច ហើយតើខ្ញុំដឹងពី WWL អចិន្ត្រៃយ៍របស់ខ្ញុំយ៉ាងដូចម្តេច?
   ច្បាប់រដ្ឋបានអនុម័តនៅខែមេសា ឆ្នាំ 2016 ។ ច្បាប់នេះបានបង្កើត WWL 40 ម៉ោងសម្រាប់ IPs ទាំងអស់ លើកលែងតែអ្នកបានធ្វើការជាមធ្យមច្រើនជាង 40 ម៉ោងសេវាកម្ម ក្នុងមួយសប្តាហ៍ក្នុងខែមករា ឆ្នាំ 2016 ។ WWLs លើសពី 40 ម៉ោង ត្រូវបានកំណត់ដោយចែកចំនួនម៉ោងសេវាកម្មដែលបង់ប្រាក់រួចក្នុងខែមករា ឆ្នាំ 2016 របស់ IP នឹង 4.33 និងបង្គត់វាទៅដប់ប្រាំនាទីដែលនៅជៀកបំផុត ។ ក្នុងខែឧសភា ឆ្នាំ  DSHS បានផ្ញើសេចក្តីជូនដំណឹងទៅ IPs ដែលបានធ្វើការក្នុងខែមករា ឆ្នាំ 2016 នូវព័ត៌មាន WWL របស់ពួកគេ ។ មិនមាន WWL អចិន្ត្រៃយ៍អាចលើសពី 65 ម៉ោងទេ ។ បើអ្នកបានចាប់ផ្តើមធ្វើការជា IP ក្រោយខែមករា ឆ្នាំ 2016   WWL របស់អ្នក គឺ 40 ម៉ោង ។

4. ចុះបើខ្ញុំគិតថា WWL អចិន្ត្រៃយ៍របស់ខ្ញុំត្រូវបានកំណត់មិនត្រឹមត្រូវ?
   បើអ្នកគិតថា WWL របស់អ្នក ត្រូវបានកំណត់មិនត្រឹមត្រូវ អ្នកអាចបញ្ជូនសំណើទៅអ្នកគ្រប់គ្រងសំណុំរឿងរបស់អតិថិជន ហើយ DSHS នឹងពិនិត្យចំនួនម៉ោងរបស់អ្នកតាមក្រមរដ្ឋបាលវ៉ាស៊ីនតោន 388-114-0050 ។

5. តើ WWL អចិន្ត្រៃយ៍របស់ខ្ញុំនឹងអាចផ្លាស់ប្តូរទេ?
   បើ WWL អចិន្ត្រៃយ៍របស់អ្នកនៅចន្លោះ 60.25 និង 65 ម៉ោង វានឹងកាត់បន្ថយមក 60 ម៉ោងនៅថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2017 លុះត្រាតែច្បាប់កែប្រែ ។ មិនដូច្នោះទេ  WWL អចិន្ត្រៃយ៍របស់អ្នក នឹងមិនផ្លាស់ប្តូរក្នុងលក្ខខណ្ឌអ្នកនៅតែមានគុណសម្បត្តិគ្រប់គ្រាន់ជា IP ។ WWL របស់អ្នក ក៏នឹងនៅរក្សាដដែល បើអ្នកសម្រាកពីសេវាកម្ម និងត្រឡប់មកជា IP នៅពេលអនាគត ។

6. តើមានសេវាកម្មអ្វីខ្លះត្រូវបានបញ្ចូលក្នុងចំនួនម៉ោងសេវាកម្មក្នុង WWL របស់ខ្ញុំ?
   - ការថែទាំផ្ទាល់ខ្លួន
   - ការថែទាំសង្គ្រោះ
   - ការបណ្តុះបណ្តាលទទួលបានជំនាញ
   - ការសម្រាកពីការថែទាំ

7. តើ WWL របស់ខ្ញុំអនុវត្តលើពេលវេលាធ្វើដំណើរ ការបណ្តុះបណ្តាលដែល DSHS តម្រូវឲ្យមាន ឬម៉ោងសម្រាកដែលបានបង់ប្រាក់រួច (PTO)?
   ទេ ។ ពេលវេលាធ្វើដំណើរ ការបណ្តុះបណ្តាលដែល DSHS តម្រូវឲ្យមាន និង PTO មិនត្រូវបានបញ្ចូលក្នុង WWL របស់អ្នកទេ ។ វាមានន័យថាអ្នកអាចធ្វើការដល់ WWL របស់អ្នក សម្រាប់អតិថិជនតាមតែចាំបាច់ ទោះក្នុងសប្តាហ៍ដែលអ្នកត្រូវបានតម្រូវឲ្យចូលរួមការបណ្តុះបណ្តាល ពេលវេលាធ្វើដំណើរដែលបានយល់ស្រប ឬយក PTO ។

# ទំព័រព័ត៌មានការធ្វើការលើសម៉ោងសម្រាប់អ្នកផ្ដល់សេវាកម្មផ្ទាល់ខ្លួន

ការបង់ប្រាក់ធ្វើការលើសម៉ោង **(OT)**

8. តើ **OT** ដែលបានបង់ប្រាក់រួចរបស់ខ្ញុំត្រូវបានគណនាយ៉ាងដូចម្ដេច?

អ្នកត្រូវបានផ្ដល់ប្រាក់ថ្លៃឈ្នួលធម្មតារបស់អ្នកសម្រាប់គ្រប់ពេលដែលអ្នកធ្វើការដល់ 40 ម៉ោងក្នុងសប្ដាហ៍ការងារ ។ សម្រាប់គ្រប់ពេលដែលអ្នកធ្វើការលើសពី 40 ម៉ោង អ្នកត្រូវបានផ្ដល់ប្រាក់ 1.5 ដង ពីថ្លៃឈ្នួលធម្មតារបស់អ្នក ។

ប្រព័ន្ធទូទាត់ IPOne បង់បរិមាណពេញនៃចំនួនម៉ោងដែលអ្នកធ្វើការក្នុងសប្ដាហ៍ការងារនៅថ្លៃឈ្នួលធម្មតារបស់អ្នក (ត្រូវបានសំដៅជា “អត្រាពេញ”) ។ វាបង្ហាញ OT ជាអត្រា ½ បន្ថែមសម្រាប់ចំនួនម៉ោង OT ។ ការសរុបទាំងនោះត្រូវបានបូកបញ្ចូលគ្នាសម្រាប់ការបង់ប្រាក់ឈ្នួលចុងក្រោយ ។

*ឧទាហរណ៍ ៖*

*អ្នកបានធ្វើការ 45 ម៉ោងក្នុងសប្ដាហ៍ការងារ ហើយអត្រាធម្មតារបស់អ្នកគឺ $12/ម៉ោង ។*

*ថ្លៃឈ្នួលរបស់អ្នក គឺ ៖*

*45 ម៉ោង x $12 ក្នុងមួយម៉ោង (អត្រាពេញ) = $540*

*+5 ម៉ោងនៃការធ្វើការលើសម៉ោង x $6 (អត្រាពាក់កណ្ដាល) = $30*

*សរុប $540 +$30 = $570*

OT ត្រូវបានបង្ហាញក្នុងការពណ៌នាការទូទាត់សង្ខេប និងត្រូវបានបំបែកក្នុងផ្នែកចំណូល ។ ក្នុងឧទាហរណ៍នេះ ផ្នែកចំណូលនឹងបង្ហាញចំនួនម៉ោងថែទាំផ្ទាល់ខ្លួន 45 និង 5 ម៉ោង OT ។

9. តើខ្ញុំនឹងត្រូវបានបង់ប្រាក់ **OT** សម្រាប់ពេលវេលាធ្វើដំណើរ ការបណ្ដុះបណ្ដាលដែល **DSHS** តម្រូវឲ្យមាន ឬម៉ោងសម្រាកដែលបានបង់ប្រាក់រួច **(PTO)** ទេ?

អ្នកនឹងត្រូវបានបង់ប្រាក់ OT សម្រាប់ពេលវេលាធ្វើដំណើរ និងការបណ្ដុះបណ្ដាលដែល DSHS តម្រូវឲ្យមាន បើចំនួនម៉ោងសរុបដែលអ្នកបានធ្វើការក្នុងសប្ដាហ៍ការងារលើសពី 40 ។ ម៉ោង PTO មិនត្រូវបានចាត់ទុកជាជាម៉ោងធ្វើការ ដូច្នេះពួកវាមិនដែលមានសិទ្ធិទទួលបានការទូទាត់ OT ទេ ។

ព័ត៌មានសម្រាប់ **IPS** ដែលមាន **WWL** អចិន្ត្រៃយ៍ **40** ម៉ោង

10. តើខ្ញុំអាចធ្វើការលើសពី **40** ម៉ោងក្នុងសប្ដាហ៍ការងារដែរទេ?

អ្នកមិនអាចធ្វើការលើសពី 40 ម៉ោងសេវាកម្មក្នុងសប្ដាហ៍ការងារទេ លុះត្រាតែអ្នកបានទទួលការយល់ស្របជាក់លាក់របស់អតិថិជនពី DSHS ដើម្បីធ្វើការជាបណ្ដោះអាសន្នលើសពី 40 ម៉ោង ។

11. តើខ្ញុំអាចធ្វើការលើសពី **WWL** អចិន្ត្រៃយ៍របស់ខ្ញុំទេ បើខ្ញុំធ្វើការឲ្យអតិថិជនច្រើន?

អ្នកត្រូវតែរៀបចំម៉ោងសេវាកម្មរបស់អតិថិជនទាំងអស់ក្នុង WWL អចិន្ត្រៃយ៍របស់អ្នក ដោយមិនគិតពីចំនួនអតិថិជនដែលអ្នកផ្ដល់សេវាកម្មឲ្យ ។ បើអ្នកធ្វើការឲ្យអតិថិជនលើសពីម្នាក់ អ្នកត្រូវតែកំណត់ពេលវេលារបស់អ្នកជាមួយពួកគេម្នាក់ៗ ដើម្បីធានាថា ពេលដែលអ្នកបូកចំនួនម៉ោងសេវាកម្មរបស់អ្នកទាំងអស់បញ្ចូលគ្នា អ្នកមិនបានធ្វើការលើសពី WWL អចិន្ត្រៃយ៍របស់អ្នក ។

12. តើខ្ញុំគួរធ្វើអ្វីខ្លះ បើអតិថិជនដែលខ្ញុំផ្ដល់សេវាកម្មឲ្យ ចង់កំណត់ពេលវេលាខ្ញុំឲ្យធ្វើការលើសពីចំនួនម៉ោងដែលខ្ញុំមានក្នុង **WWL** អចិន្ត្រៃយ៍របស់ខ្ញុំ?

- ពន្យល់ថាអ្នកមិនត្រូវបានអនុញ្ញាតឲ្យធ្វើការលើសពី WWL របស់អ្នក ហើយបើធ្វើដូច្នោះ នឹងត្រូវបានចាត់ចូលជាការទាមទារលើស ។ សូមមើល #19 សម្រាប់ព័ត៌មានបន្ថែម ស្ដីពីការទាមទារលើស
- កុំទទួលការងារដែលនឹងបង្កឲ្យអ្នកធ្វើការលើសពី WWL របស់អ្នក ។
- លើកទឹកចិត្តឲ្យអតិថិជនប្រើអ្នកផ្ដល់សេវាកម្មបន្ថែម ។
- លើកទឹកចិត្តអតិថិជនឲ្យទាក់ទងអ្នកគ្រប់គ្រងសំណុំរឿងរបស់គាត់ បើអតិថិជនមានការលំបាកក្នុងការយល់ពីការកម្រិតរបស់អ្នក ឬមិនអាចស្វែងរកអ្នកផ្ដល់សេវាកម្មបន្ថែមបាន ។
- សូមមើល #18 នៅទំព័រ 3 សម្រាប់ព័ត៌មានបន្ថែមពីតម្រូវការបន្ទាន់ និងភ្ញាមៗ ។

ព័ត៌មានសម្រាប់ **IPS** ដែលមាន **WWL** អចិន្ត្រៃយ៍នៃចំនួនម៉ោង **40.25** ឬច្រើនជាងនេះ

**13.** តើខ្ញុំអាចធ្វើលើសពី **40** ម៉ោងក្នុងសប្ដាហ៍ការងារទេ?

បើអ្នកបានទទួលសេចក្ដីជូនដំណឹងជាលាយលក្ខណ៍ពី DSHS ថា WWL អចិន្ត្រៃយ៍របស់អ្នកលើសពី 40 ឬបើអ្នកមានអតិថិជនបច្ចុប្បន្នបានយល់ស្របបង្កើន WWL ជាក់លាក់ អ្នកអាចធ្វើការដល់ចំនួនម៉ោងលើសេចក្ដីជូនដំណឹងរបស់អ្នក ។

**14.** តើខ្ញុំគួរតែអ្វីខ្លះ បើខ្ញុំធ្វើការលើសពីអតិថិជនម្នាក់?

សូមមើលចម្លើយសំណួរ #11 ។

**15.** ចុះបើអតិថិជនដែលខ្ញុំធ្វើការជូន ចង់ឲ្យខ្ញុំសម្រួលចំនួនម៉ោងដើម្បីធ្វើការលើសពី **WWL** អចិន្ត្រៃយ៍របស់ខ្ញុំក្នុងមួយសប្ដាហ៍?

អ្នកអាចសម្រួលចំនួនម៉ោងរបស់អ្នក បើចំណុចខាងក្រោមទាំងអស់ជាការពិត ៖

- អតិថិជនមានតម្រូវការ និង
- ការធ្វើការម៉ោងបន្ថែមនឹងមិនលើសចំនួនម៉ោងដែលបានវាយតម្លៃប្រចាំខែរបស់អតិថិជន និង
- ការធ្វើការបន្ថែមក្នុងមួយសប្ដាហ៍នឹងមិនផ្ដល់លទ្ធផលក្នុងអតិថិជនទៅដោយគ្មានការថែទាំសំខាន់ក្នុងសប្ដាហ៍ផ្សេងនៃខែ និង
- ការធ្វើការបន្ថែមក្នុងមួយសប្ដាហ៍ នឹងមិនបង្កឲ្យអ្នកធ្វើការលើសម៉ោងកាន់តែច្រើនក្នុងខែជាងដែលអ្នកនឹងធ្វើ បើអ្នកបានធ្វើការដល់ WWL របស់អ្នករៀងរាល់សប្ដាហ៍នៃខែនោះ ។

ពេលដែល WWL របស់អ្នកលើសពី 40 អ្នកអាចសម្រួលចំនួនម៉ោងរបស់អ្នកតាមតែចាំបាច់ក្នុងករណីដែលអ្នកមិនធ្វើការលើសម៉ោងច្រើនក្នុងខែជាងអ្នកនឹងធ្វើការធម្មតា ។ បរិមាណនៃចំនួនម៉ោងធ្វើការលើសម៉ោងប្រចាំខែត្រូវបានគណនាដោយការដក 40 ម៉ោងពី WWL របស់អ្នក ហើយគុណអ្វីដែលនៅសល់ជាមួយចំនួនថ្ងៃសៅរ៍ក្នុងខែនោះ ។

*<u>ឧទាហរណ៍ ៖</u>*

*WWL របស់ Jose គឺ 46 ម៉ោង ។ បរិមាណធ្វើការលើសម៉ោងប្រចាំខែ ដែល Jose អាចធ្វើការផ្អែកលើចំនួនថ្ងៃសៅរ៍ក្នុងខែដែលគាត់កំពុងធ្វើការ។*

*ការគណនា **5** ថ្ងៃសៅរ៍ ៖ 46 – 40 = 6 x 5 = 30*

*ការគណនា **4** ថ្ងៃសៅរ៍ ៖ 46-40=6 x 4 = 24*

*អតិថិជនដែល Jose ធ្វើការជូន ត្រូវការគាត់ធ្វើការក្នុងពេលវេលាអាចបត់បែនពាសពេញខែ ដែល Jose អាចធ្វើការបាន ក្នុងលក្ខខណ្ឌដែលគាត់មិនធ្វើការលើសពី 30 ម៉ោងនៃការធ្វើការលើសម៉ោងក្នុងខែជាមួយ 5 ថ្ងៃសៅរ៍ ឬ 24 ម៉ោងនៃការធ្វើការលើសម៉ោងក្នុងខែជាមួយ 4 ថ្ងៃសៅរ៍ ។*

អ្នកក៏អាចសម្រួលចំនួនម៉ោងរបស់អ្នកដើម្បីធ្វើការលើសពី WWL របស់អ្នក បើអតិថិជនដែលអ្នកធ្វើការជូន កំពុងទិញចំនួនម៉ោងធ្វើការលើសម៉ោងបន្ថែមជាមួយថវិកាសេវាកម្មសេរីភាពថ្មី ឬការថែទាំនៅផ្ទះដែលណែនាំដោយអតីតយុទ្ធជនរបស់ពួកគេ ។

**16.** តើខ្ញុំគួរតែអ្វីខ្លះ បើអតិថិជនដែលខ្ញុំធ្វើការជូន ចង់កំណត់ពេលវេលាខ្ញុំធ្វើការលើសចំនួនធ្វើការលើសម៉ោងប្រចាំខែសរុបជាងខ្ញុំមានក្នុង **WWL** អចិន្ត្រៃយ៍របស់ខ្ញុំ? សូមមើលចម្លើយសំណួរ #12 ។

ការកម្រិតបណ្ដោះអាសន្ននៃសប្ដាហ៍ការងារដែលអតិថិជនបញ្ជាក់ច្បាស់ **(CSWWL)**

**17.** តើអ្វីជា **CSWWL** បណ្ដោះអាសន្ន?

អតិថិជនដែលអ្នកធ្វើការជូន អាចស្នើសុំ DSHS បង្កើនជាបណ្ដោះអាសន្ននូវ WWL របស់អ្នក ខណៈដែរគាត់ស្វែងរកអ្នកផ្ដល់សេវាកម្មបន្ថែមដើម្បីបំពេញតម្រូវការរបស់ពួកគេ ។ DSHS នឹងឆ្លើយតបអ្នកតាមសំបុត្រជាមួយការយល់ស្រប ឬបដិសេធជាលាយលក្ខណ៍ ។ បើត្រូវបានយល់ស្រប សេចក្ដីជូនដំណឹងក៏នឹងប្រាប់អ្នកនូវកាលបរិច្ឆេទយល់ស្របចាប់ផ្ដើម និងបញ្ចប់ និងចំនួនម៉ោងដែលបានយល់ស្រប ។ អតិថិជនដែលអ្នកផ្ដល់សេវាកម្មជូន ក៏នឹងទទួលច្បាប់ចម្លង ។ សំណើនេះ/ការជូនដំណឹងជាលាយលក្ខណ៍ក៏ត្រូវស្គាល់ជាសំណើ CSWWL ។ DSHS នឹងមិនយល់ស្រប WWL បណ្ដោះអាសន្ន ដែលលើសចំនួនម៉ោងប្រចាំខែដែលបានវាយតម្លៃរបស់អតិថិជន ។

តម្រូវការបន្ទាន់

18. តើខ្ញុំគួរតែអ្វីខ្លះ បើខ្ញុំបានធ្វើការក្នុងម៉ោងទាំងអស់នៃ WWL របស់ខ្ញុំ ប៉ុន្តែអតិថិជនមានតម្រូវការបន្ទាន់ និងភ្លាមៗ ហើយខ្ញុំត្រូវតែបន្តធ្វើការដើម្បីជួយសុខភាព ឬសុវត្ថិភាពរបស់អតិថិជន?
    - នៅជាមួយអតិថិជនរហូតដល់ស្ថានភាពមានសុវត្ថិភាព និងនឹងនរ ។
    - បើមានការសង្គ្រោះបន្ទាន់ ដែលតម្រូវឲ្យមានសេវាកម្មវេជ្ជសាស្ត្រសង្គ្រោះបន្ទាន់ សូមទាក់ទង 9-1-1 ។
    - បញ្ចប់ម៉ោងធ្វើការរបស់អ្នកឲ្យបានឆាប់ បើមានសុវត្ថិភាពក្នុងការធ្វើដូច្នោះ ។
    - ទាក់ទងអ្នកគ្រប់គ្រងសំណុំរឿងត្រឹមថ្ងៃធ្វើការបន្ទាប់ ដើម្បីពន្យល់ពីស្ថានភាព ។

ការទាមទារលើស

19. តើអ្វីជាការទាមទារលើស?
    ការទាមទារលើសកើតឡើងនៅពេលដែល ៖
    - អ្នកធ្វើលើសចំនួនម៉ោងសេវាកម្មក្នុងខែជាងអ្នកត្រូវបានផ្តល់សិទ្ធិ ឬ
    - អ្នកធ្វើលើសចំនួនម៉ោង WWL របស់អ្នក ដែលមិនត្រូវបានយល់ស្របដោយ DSHS ឬ
    - អ្នកទាមទារពេលវេលាធ្វើដំណើរច្រើនជាងអ្នកត្រូវបានផ្តល់សិទ្ធិ ដើម្បីផ្តល់សេវាកម្មក្នុងសប្តាហ៍ការងារ ។

20. តើអ្វីជាចំណាត់ការកិច្ចសន្យា?
    ចំណាត់ការកិច្ចសន្យាគឺជាសេចក្តីជូនដំណឹងផ្ញើឲ្យអ្នកដោយ DSHS ។ សេចក្តីជូនដំណឹងប្រាប់អ្នកថាអ្នកបានធ្វើការលើសចំនួនម៉ោងសេវាកម្មធ្វើការលើសម៉ោង ឬពេលវេលាធ្វើដំណើរជាងអ្នកត្រូវបានយល់ស្របឲ្យធ្វើការ ។

21. តើមានអ្វីកើតឡើង បើខ្ញុំធ្វើការលើសពី WWL របស់ខ្ញុំ ឬការកម្រិតពេលវេលាធ្វើដំណើរ?
    - រាល់ពេលដែលអ្នកទាមទារលើស អ្នកនឹងទទួលបានសេចក្តីជូនដំណឹងពីចំណាត់កិច្ចសន្យាជាលាយលក្ខណ៍អក្សរ និងព័ត៌មានពី DSHS រំលឹកអ្នកពីសារៈសំខាន់នៃការមិនធ្វើការក្នុងការធ្វើលើសម៉ោងដែលមិនបានផ្តល់សិទ្ធិ ។ សេចក្តីជូនដំណឹងក៏នឹងត្រូវបានផ្ញើទៅអតិថិជនដែលអ្នកផ្តល់សេវាកម្មជូន និងអ្នកតំណាងរបស់ពួកគេ ។
    - នៅករណីទីបីនៃការទាមទារលើស កិច្ចសន្យារបស់អ្នកអាចត្រូវបានលុបចោល ឬអ្នកអាចក្លាយជាគ្មានសិទ្ធិទទួលបានការទូទាត់សម្រាប់រយៈពេល 90 ថ្ងៃ ។ បើកិច្ចសន្យារបស់អ្នកត្រូវបានលុបចោល អ្នកត្រូវតែរង់ចាំ 90 ថ្ងៃ មុនអ្នកមានសិទ្ធិទទួលបានកិច្ចសន្យាថ្មី ។
    - បើអ្នកលើសច្រើន ឬជាដដែលៗនូវសប្តាហ៍ការងារ ឬការកម្រិតពេលវេលាធ្វើដំណើររបស់អ្នក DSHS អាចលុបចោលកិច្ចសន្យារបស់អ្នកសម្រាប់ការមិនគោរពកិច្ចសន្យា និងបដិសេធការចុះកិច្ចសន្យាម្តងទៀតជាមួយអ្នក ។

22. តើរយៈពេលប៉ុន្មានដែលចំណាត់ការកិច្ចសន្យានឹងស្ថិតក្នុងឯកសារកិច្ចសន្យារបស់ខ្ញុំ?
    ចំណាត់ការកិច្ចសន្យានីមួយៗនឹងនៅបើកចំហររយៈពេល 12 ខែ ពីកាលបរិច្ឆេទនៃសេចក្តីជូនដំណឹងពីចំណាត់ការកិច្ចសន្យា ។ ក្រោយពី 12 ខែ ចំណាត់ការកិច្ចសន្យាត្រូវបានបិទ ។

23. តើខ្ញុំអាចជៀសវាងចំណាត់ការកិច្ចសន្យាយ៉ាងដូចម្តេច?
    - តែងតែរៀបចំពេលវេលាធ្វើការរបស់អ្នកជាមុន និងសសេរជាទុក ។
    - បើតម្រូវការអតិថិជនណាផ្លាស់ប្តូរ ហើយអ្នកត្រូវធ្វើការក្នុងពេលវេលាផ្សេង ដែលប៉ះពាល់ WWL របស់អ្នក សូមទាក់ទងអ្នកគ្រប់គ្រងសំណុំរឿងរបស់អតិថិជនភ្លាមៗ ។
    - កត់ត្រាពេលវេលាធ្វើការរបស់អ្នកលើតារាងកត់ម៉ោងធ្វើការរបស់អ្នករាល់ថ្ងៃដែលអ្នកធ្វើការ វាក៏អាចជួយក្នុងការកត់ត្រាវាលើប្រតិទិនក្រដាស ។ ពិនិត្យជារឿយៗ ដើម្បីធានាថាអ្នកស្ថិតក្នុង WWL របស់អ្នក ។
    - DSHS មានធនធានដើម្បីជួយអ្នក និងនិយោជក/អតិថិជនរបស់អ្នកសិក្សាបន្ថែមអំពីការគ្រប់គ្រងការកំណត់ពេលរបស់អ្នកឲ្យនៅក្នុង WWL របស់អ្នក ។ ធានធនទាំងនេះ មាននៅ **www.dshs.wa.gov/altsa/IPOT** ។